ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ ១០៥/២៣ រ.ប.ក

**របាយការណ៍ខែឧសភា**
**ស្តីពី**
**ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ**
**និងទិសដៅខែមិថុនា ឆ្នាំ២០២៣**

## I. ស្ថានភាពទូទៅ

ក្រសួង ស្ថាប័ន រាជធានី ខេត្ត នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះប្រទេសជាតិ បាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តន៍ថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងការជះឥទ្ធិពលពីការប្រែប្រួលនៃសភាពការណ៍ពិភពលោក ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរ៉ាំរ៉ៃនៅបណ្តាប្រទេសមួយចំនួន គ្រោះធម្មជាតិ( ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ...) និងថែមទាំងគ្រោះមហន្តរាយដោយការរាតត្បាតដោយវីរុសកូវីដ-១៩ និងមេរោគបម្លែងថ្មី។

ក្រោយពីពិភពលោកកំពុងតែប្រយុទ្ធប្រឆាំងនឹងវិបត្តិជំងឺកូវីដ-១៩ មិនទាន់បានចប់ផង ក៏មានព្រឹត្តិការណ៍ថ្មីមួយទៀត ចាប់ពីខែ កុម្ភៈ ឆ្នាំ២០២២ មកដល់ពេលបច្ចុប្បន្ននេះមានការផ្ទុះសង្គ្រាមរវាងប្រទេសរុស្ស៊ី និងប្រទេសអ៊ុយក្រែន បានបង្កឱ្យមានវិបត្តិសេដ្ឋកិច្ចទូទាំងសកលលោក ដូចជាប្រេង និងឧស្ម័ន បានឡើងថ្លៃខ្ពស់ ហេតុធ្វើឱ្យប្រទេសមួយចំនួនមានសេដ្ឋកិច្ចធ្លាក់ចុះយ៉ាងខ្លាំង និងមានវិបត្តិជំពាក់បំណុលគេដ៏ធ្ងន់ធ្ងរ ដែលមិនអាចដោះស្រាយបាន។

រាជរដ្ឋាភិបាលយើងបាន និងកំពុងតែ យកចិត្តទុកដាក់យ៉ាងខ្លាំង លើកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋ ដែលបង្កដោយការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ-១៩ និងផលប៉ះពាល់ដ៏ធំធេងលើ ជីវភាព និងសុខភាពប្រជាពលរដ្ឋ ព្រមទាំងសេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរ ជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ នូវផែនការសកម្មភាពនានា ដែលបានគ្រោងទុក និងត្រូវបន្ថែមភារកិច្ចក្នុងការដោះស្រាយ ទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ចំណែកឯប្រជាជនយើង មួយចំនួននៅតែមើលស្រាលស្ថានភាព មិនស្តាប់ការអប់រំណែនាំ មិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្តាប់ និងជឿការអូសទាញ ភូតភរពីមេខ្យល់ ធ្វើឱ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស និងខាតបង់ទាំងទ្រព្យសម្បត្តិ និងកម្លាំងកាយ រហូតដល់ធ្លាក់ខ្លួនឈឺដ៏ធ្ងន់ធ្ងរថែមទៀត។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាពជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ

ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ-១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ១. ការកសាងច្បាប់

- **ក្រសួងយុត្តិធម៌** បានរៀបចំបន្តពិនិត្យសេចក្តីព្រាងច្បាប់ស្តីពី «អំពើពពោះជំនួស» និងច្បាប់ស្តីពី «ការប្រឆាំងអំពើរត់ពន្ធមនុស្ស»។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន និងកំពុងសិក្សារៀបចំសេចក្តីព្រាងច្បាប់ស្តីពី «ទេសន្តរប្រវេសន៍ការងារកម្ពុជានៅបរទេស»។

#### ២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ» ជាមួយសាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋបេឡារុស និងសាធារណរដ្ឋតួកគី។
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «បត្យាប័ន» ជាមួយសាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋបេឡារុស និងសាធារណរដ្ឋតួកគី។
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «ការផ្ទេរទណ្ឌិត» ជាមួយសាធារណរដ្ឋប៉េរូ សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋតួកគី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងព្រះរាជាណាចក្របែលហ្សិក។

### ខ. ការបង្ការ ទប់ស្កាត់

#### ១. តាមរយៈការលើកកម្ពស់ការយល់ដឹង

##### ១.១. ការអប់រំដោយផ្ទាល់

##### ១.១.១. កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយសាធារណៈ

នៅក្នុងខែឧសភា ឆ្នាំ២០២៣នេះ ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយស្តីពី ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព**" ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន **១២.១៩៤**លើក មានអ្នកចូលរួមសរុបចំនួន **៦៤៦.៦៥៥**នាក់ ស្ត្រីចំនួន **២៤១.៣៧០**នាក់ (ធៀបនឹងខែមេសា មានចំនួន **៦១៦.៤៩៦**នាក់ គឺមានការកើនឡើងចំនួន ៣០.១៥៩នាក់ ស្មើនឹង៤,៨៩%) ក្នុងនោះ ដូចមានតារាងលម្អិតខាងក្រោម៖

## តារាងទិន្នន័យកិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| **ក្រសួង ស្ថាប័ន** | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៤៩ | ៧.១៧៥ | ៤.០៧២ | ៥១៥ | ១៥.៤១១ | ៨.៧១៤ |
| | សរុប ក្រសួង ស្ថាប័ន | ៤៩ លើក | ៧.១៧៥ នាក់ | ៤.០៧២ នាក់ | ៥១៥ លើក | ១៥.៤១១ នាក់ | ៨.៧១៤ នាក់ |
| **រាជធានី-ខេត្ត** | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្ដាល | ១.០០១ | ៥២.២០៣ | ២៥.៦៥៥ | ១.៥៥៧ | ១០៦.៦៧៤ | ៥៣.០៨៦ |
| ៣ | ខេត្តបាត់ដំបង | ៨២៤ | ៤៧.៥៧៣ | ២៤.០០៣ | ៦០៥ | ២៤.៩៩៥ | ១២.៣៧៥ |
| ៤ | ខេត្តពោធិ៍សាត់ | ៤៣១ | ៣៤.២២៩ | ១៥.៦២១ | ១២៦ | ៤.៣៧១ | ២.១៧២ |
| ៥ | ខេត្តសៀមរាប | ២២៤ | ១៥.៨៧៧ | ៨.៩១៦ | ៤២ | ១.៤៩១ | ៩៤៥ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៨០៤ | ២១.៦៧១ | ១១.២៣៥ | ៣៨៤ | ១០.៣១៤ | ៥.២៨២ |
| ៧ | ខេត្តកំពង់ចាម | ១.៧០៩ | ៩០.២៥៨ | ៤៥.៦៣៩ | ១ | ៣១ | ១៦ |
| ៨ | ខេត្តព្រះសីហនុ | ១៨ | ៥.៤១៤ | ២.៥៤០ | | | |
| ៩ | ខេត្តព្រះវិហារ | | | | | | |
| ១០ | ខេត្តស្វាយរៀង | ២ | ៣៥៦ | ៦១ | ៣៣៩ | ១០.៨៣៩ | ៦.៣២២ |
| ១១ | ខេត្តប៉ៃលិន | ៧៤ | ១.០៤២ | ៣០៧ | ៣៨ | ១.៥៨០ | ៤១៥ |
| ១២ | ខេត្តកោះកុង | ១ | ៥២ | ៤១ | ១២៣ | ១.៩០៨ | ៩៤៣ |
| ១៣ | ខេត្តកំពត | ១ | ២៧០ | ១៨០ | | | |
| ១៤ | ខេត្តកំពង់ធំ | ៦៩៨ | ១៣៣.៩៥៦ | ៨១.៥០៩ | ៣១ | ១.៧២៥ | ១.០៤៨ |
| ១៥ | ខេត្តតាកែវ | ២២៧ | ៧.៦៩២ | ៣.៧៨៤ | ៧៦ | ២.៤៦៥ | ១.២០២ |
| ១៦ | ខេត្តក្រចេះ | ៩ | ៣៥៥ | ២៣០ | | | |
| ១៧ | ខេត្តកែប | ៣៣ | ៦.៦៦៥ | ៥.២៦៥ | ៥៤ | ២.៤៧៦ | ១.៤៦០ |
| ១៨ | ខេត្តកំពង់ស្ពឺ | ៣៨ | ២.៨២៤ | ១.១៧៦ | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | ៥៣ | ៤.៨៤៤ | ២.៧៥៨ | ១៨ | ៩៨០ | ៨០២ |
| ២២ | ខេត្តត្បូងឃ្មុំ | ៤ | ២.៥៥៦ | ១.៤៧៤ | ២.០៨៥ | ២៦.៣៨៣ | ១១.២២២ |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្ដរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| | សរុប រាជធានី-ខេត្ត | ៦.១៥១លើក | ៤២៧.៨៣៧នាក់ | ២៣១.២៩៤នាក់ | ៥.៤៧៩លើក | ១៩៦.២៣២នាក់ | ៩៧.២៩០នាក់ |
| | សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | ចំនួន ១២.១៩៤ លើក | | ចំនួនមនុស្សសរុប ៦៤៦.៦៥៥ នាក់ | | ចំនួនស្ត្រី ២៤១.៣៧០ នាក់ | |

### ១.១.២. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- **ខេត្តកំពង់ចាម៖**
  - **ក្រុមការងារទេសន្តរប្រវេសន៍ ដឹកនាំដោយមន្ទីរការងារ** សហការជាមួយសមាគមជ្រើសរើសពលករកម្ពុជា និងក្រុមហ៊ុនអ៊ឹង រិទ្ធី គ្រុប រៀបចំវគ្គផ្សព្វផ្សាយស្តីពីការទទួលខុសត្រូវ និងក្រមសីលធម៌ក្នុងការជ្រើសរើសពលករ មានអ្នកចូលរួមសរុប ៨០នាក់ ស្រី៤០នាក់។
  - **រដ្ឋបាល ស្រុកចំការលើ៖** អាជ្ញាធរមូលដ្ឋានឃុំជយោ ភូមិជយោត្បូង បានសហការជាមួយអង្គការភ្នំស្រីដើម្បីអភិវឌ្ឍន៍ ដើម្បីចុះផ្សព្វផ្សាយអំពីការចំណាកស្រុកប្រកបដោយសុវត្ថិភាព និងវិធីបង្ការការពារនៃជំងឺ covid-19 ដែលមានអ្នកចូលរួមសរុប ៣១នាក់ ស្រី១៦នាក់។

- **ខេត្តកណ្ដាល៖** មន្ទីរអប់រំយុវជន និងកីឡា បានបញ្ជ្រាបការផ្សព្វផ្សាយអំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅពេលគោរពទង់ជាតិរាល់ព្រឹកថ្ងៃច័ន្ទ និងតាមរយៈកិច្ចប្រជុំប្រចាំខែ មានអ្នកចូលរួមសរុប **១៨០**នាក់ ស្រី**៤២**នាក់។
- **ខេត្តពោធិ៍សាត់៖** មន្ទីរអប់រំបានផ្សព្វផ្សាយអំពីការជួញដូរគ្រឿងញៀន ការរំលោភបំពានផ្លូវភេទ ផ្លូវកាយ ផ្លូវអារម្មណ៍ ការជួញដូរមនុស្ស និងការប្រើអំពើហិង្សា ដល់ប្រជាពលរដ្ឋ សិស្សានុសិស្ស យុវជន និងកុមារ បានចំនួន **២៩**លើក មានអ្នកចូលរួមសរុប **៥.៦៧៩**នាក់ ស្រី **២.៨១២**នាក់។
- **ខេត្តក្រចេះ៖**
  - **មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍មន្ទីរ** បានផ្សព្វផ្សាយការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្ដីពីវិធីទប់ស្កាត់ និងការរំលោភបំពានផ្លូវភេទគ្រប់រូបភាព ដល់មន្ត្រីគ្រប់ជាន់ថ្នាក់និងបានផ្សព្វផ្សាយបន្តនៅតាមសហគមន៍ ឬភូមិឃុំ និងនិយោជិកក្រុមហ៊ុនបញ្ញើប្រៃសណីយ៍ អាជីវករលក់ទូរស័ព្ទ និងនិយោជិកក្រុមហ៊ុនផ្ដល់សេវាអ៊ិនធឺណែត។
  - **មន្ទីរអប់រំ យុវជន និងកីឡា** បានចុះផ្សព្វផ្សាយពីរបៀបធ្វើទិវាទប់ស្កាត់ការជួញដូរមនុស្ស នៅអនុវិទ្យាល័យក្បាលបឹងវែ និងវិទ្យាល័យជីដុះ ស្រុកព្រែកប្រសព្វ ០២លើក ដែលមានសិស្សានុសិស្ស និងមាតាបិតាសិស្ស ចូលរួមសរុបចំនួន**៥៩៤**នាក់ ស្រី**៣១១**នាក់។
- **ខេត្តកំពង់ឆ្នាំង៖**
  - មន្ទីរអប់រំ យុវជន និងកីឡា បានបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនឹងការជួញដូរមនុស្ស តាមរយៈកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ដល់ប្រធានការិយាល័យអប់រំ រដ្ឋបាលក្រុង ស្រុកទាំង៨ និងសិស្សានុសិស្ស នៅក្នុងពេលគោរពទង់ជាតិមុនចូលរៀន និងនៅក្នុងមេរៀនដែលពាក់ព័ន្ធ ចំនួន ០៨លើក។
  - ស្រុកទឹកផុសបានចុះផ្សព្វផ្សាយច្បាប់ស្ដីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស តាមរយៈកិច្ចប្រជុំគណៈបញ្ជាការឯកភាព កិច្ចប្រជុំ គ.ក.ស.ក និងកិច្ចប្រជុំសមាគមនារីដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ចំនួន ០៣លើក មានអ្នកចូលសរុបចំនួន **៦៣**នាក់ ស្រី **១៥**នាក់។
  - ស្រុកសាមគ្គីមានជ័យ បានផ្សព្វផ្សាយស្ដីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ តាមរយៈកិច្ចប្រជុំ គ.ក.ស.ក ប្រចាំខែ មានអ្នកចូលរួម **២២**នាក់ ស្រី **១២**នាក់។
- **ខេត្តតាកែវ៖** លោកស្រីអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានចុះមូលដ្ឋានជួបជាមួយប្រជាពលរដ្ឋនៅឃុំផ្លាប្រជុំ ស្រុកកោះអណ្ដែត និងសួរសុខទុក្ខ ចំនួន ០២គ្រួសារ ដែលមានជំងឺសម្រាកនៅផ្ទះ ព្រមទាំងបានចូលរួមសម្របសម្រួល ទទួលបងប្អូនប្រជាពលរដ្ឋចំណាកស្រុក និងផ្សព្វផ្សាយការទប់ស្កាត់អំពើជួញដូរមនុស្ស ការរត់ពន្ធមនុស្ស និងអំពើហិង្សាក្នុងគ្រួសារចំនួន ០១លើក មានអ្នកចូលរួមចំនួន ៨៨នាក់ ស្រី៤៥នាក់។
- **ខេត្តបន្ទាយមានជ័យ៖**
  - **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចុះចងបជា និងផ្សព្វផ្សាយការទប់ស្កាត់ពលកម្មកុមារក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ នៅភូមិថ្មសិន សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត។
  - **មណ្ឌលសំចតប៉ោយប៉ែត** សហការជាមួយអង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) ដើម្បីផ្សព្វផ្សាយស្ដីពី ការសង្គ្រោះបឋមសុខភាពផ្លូវចិត្តដល់ពលករពលការិនី ដែលវិលត្រឡប់មកពីប្រទេសថៃ បានចំនួន ៨៩០នាក់ ស្រី ៣៤៧នាក់។
  - **មណ្ឌលធនធានពលករទេសន្តរប្រវេសន៍** បានចុះផ្សព្វផ្សាយតាមសហគមន៍ស្ដីពី សុវត្ថិភាពចំណាកស្រុក បានចំនួន ៨ស្រុក( ស្វាយចេក ថ្មពួក ព្រះនេត្រព្រះ មង្គលបូរី ម៉ាឡៃ ភ្នំស្រុក អូរជ្រៅ និងក្រុងសិរីសោភ័ណ ) មានអ្នកចូលរួមសរុប **៦១២**នាក់ ស្រី**១៤៦**នាក់( អតីតពលករ **១៥២**នាក់ ស្រី**១០០**នាក់ )។

- **អង្គការតំណក់ទឹក** បានចុះធ្វើបណ្ណាល័យចល័ត ដើម្បីអប់រំដល់ក្រុមយុវជន និងគ្រួសារ ស្តីពីចំណាកស្រុកប្រកបដោយសុវត្ថិភាព អ្នកចូលរួម ៨៥នាក់ ស្រី៣៨នាក់។
- **អង្គការអន្តរជាតិទេសន្តរប្រវេសន៍(IOM)៖** ១.បានប្រឹក្សាយោបល់ដោយផ្ទាល់ជាលក្ខណៈឯកជនជាមួយពលករ ដូចជា ពលករទេសន្តរប្រវេសន៍៤៧នាក់ ពលករមានឱកាសទទួលបានការងារក្នុងស្រុក២២នាក់ និងផ្តល់ការជំនាញវិជ្ជាជីវៈ៣១នាក់ ហើយបានបញ្ជ្រាបអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពផងដែរ។ ២.ធ្វើការអប់រំផ្សព្វផ្សាយអំពីការបង្ការជំងឺកូវីត-១៩ និងជំងឺរបេង ជំងឺផ្លូវដង្ហើមផ្សេងៗ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ជនចំណាកស្រុកនៅមណ្ឌលសុខភាពនិងស្រុកប្រតិបត្តិ បានចំនួន **១.២៧៣**នាក់។

- **ខេត្តព្រះសីហនុ៖** លោកស្រីប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានធ្វើការផ្សព្វផ្សាយអប់រំ អំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកំលាំងពលកម្ម និងការធ្វើចំណាកស្រុកខុសច្បាប់ ក្នុងឱកាសនៃការចូលរួមយុទ្ធនាការ អប់រំសហគមន៍ ស្តីពីសុខភាពភ្នែក (កំហុសកំណុំរូបភាព) ដែលរៀបចំនិងសម្របសម្រួលដោយមន្ទីរកិច្ចការនារីខេត្ត សហការជាមួយមន្ត្រីអង្គាធរមូលដ្ឋាន នៅឃុំអណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានអ្នកចូលរួម **២១០**នាក់ ស្រី **១២៨**នាក់ ។
- **ខេត្តបាត់ដំបង៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ពលករបញ្ជូនត្រឡប់ពីប្រទេសថៃនៅមណ្ឌលទទួលពលកំរៀង ចំនួន **១២៦**នាក់ ស្រី **៥១**នាក់។

**១.១.៣. ការផ្សព្វផ្សាយរបស់អង្គការដៃគូ**

- **ខេត្តបន្ទាយមានជ័យ៖ អង្គការកល្យាណមិត្ត** បានចុះធ្វើកម្មវិធីអប់រំផ្សព្វផ្សាយស្តីពី ការចំណាកស្រុកដោយសុវត្ថិភាព និងចែកសម្ភារៈដល់ប្រជាពលរដ្ឋក្នុងសហគមន៍ចំនួន **២៨៨**នាក់ ស្រី**២១២**នាក់។

**១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានផ្សព្វផ្សាយព័ត៌មាន និងច្បាប់ពាក់ព័ន្ធ ស្តីពីការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមរយៈគេហទំព័រហ្វេសប៊ុក មានអ្នកចូលទស្សនាចំនួន **២.១៧៦**នាក់។
- **ខេត្តសៀមរាប៖** មន្ទីរព័ត៌មានបានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុជាតិនគរភ្នំ និងទូរទស្សន៍ជាតិខេត្តសៀមរាប ស្តីពីអំពើការទប់ស្កាត់ហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ វិធានការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត ការស្វែងរកការងារក្នុងស្រុកជាជាងការចំណាកដោយប្រថុយប្រថាន បានចំនួន**៧៩**លើក ក្នុងនោះបានធ្វើការផ្សាយផ្ទាល់ ចំនួន**៣៥**លើក និងចាក់ផ្សាយឡើងវិញ ចំនួន**៤៤**លើក។
- **ខេត្តព្រៃវែង៖** មន្ទីរព័ត៌មានបានធ្វើការផ្សព្វផ្សាយសារអប់រំស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមរយៈវិទ្យុបាពយណ៍អណ្តែត ចំនួន **៥០**លើក។

**១.៣. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)**

- **ខេត្តបន្ទាយមានជ័យ៖**
  - **អង្គការសាម៉ារីតាន់ភឺស** ផ្តល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់មនុស្សចំនួន **៥៦៨**នាក់(ស្រី**២១០**នាក់) កុមារ **៦៧**នាក់(កុមារី**៣៥**នាក់)។
  - **អង្គការ** UNFPA ចែកខិត្តប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងបានចែកកញ្ចប់ឃីតចំនួន **៨០**កញ្ចប់ដល់ពលករ។

- **ខេត្តបាត់ដំបង៖ អង្គការសាម៉ារីតាន់ភឺស** បានធ្វើការចាក់ឃោសនស័ព្ទផ្សព្វផ្សាយ និងចែកខិត្តប័ណ្ណស្តីពីការចំណាកស្រុកដោយសុវត្ថិភាព ការទប់ស្កាត់ការជួញដូរមនុស្ស និងខិតប័ណ្ណការបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ សរុបចំនួន **៩០០**សន្លឹក ចំនួន ០៤ភូមិ ភូមិអូរ ភូមិទឹកផុស ភូមិប្រឡាយប្រាក់ និងភូមិស្រឡៅជ្រុំ មានអ្នកចូលរួមចំនួន **៤៩៣**នាក់ (ប្រុស៣២នាក់ ស្រី៩៧នាក់ កុមារ ១១២នាក់ កុមារី២៥២នាក់)។

**១.៤. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ**

- **ខេត្តកំពង់ចាម៖** តំណាងស្នងការដ្ឋាននគរបាល បានចូលរួមជាវាគ្មិននៅវិទ្យុជាតិខេត្ត ០១លើក ក្រោមប្រធានបទ ការចូលរួមទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

**២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ**

**២.១. ការបង្កើតកម្មវិធីសិក្សា ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស**

- **ខេត្តបន្ទាយមានជ័យ៖ អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM)** បានបើកវគ្គតម្រង់ទិសស្តីពី ធ្វើការសម្រេចចិត្តដែលប្រកបដោយសុវត្ថិភាព ដើម្បីណែនាំដល់ពលករវិលត្រឡប់មកពីថៃ និងម៉ាឡេស៊ី ចំនួន **១.៤០២**នាក់ ស្រី**៥៥២**នាក់។

**២.២. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក**

- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុក ទៅក្រៅប្រទេសទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន **២២១.៨៣០**នាក់ (ស្រី**៩៩.៦៨៩**នាក់) អនីតិជន **៣.៦៦៦**នាក់(ស្រី**១.២៩២**នាក់) ក្នុងនោះមាន៖
    - ស្របច្បាប់ ចំនួន **១៦៨.៧១១**នាក់ (ស្រី**៧៦.៩៤៤**នាក់) អនីតិជន **៤០៤**នាក់(ស្រី**១.២៩២**នាក់)
    - មិនស្របច្បាប់ចំនួន **៥២.៥៧១**នាក់ (ស្រី**២២.៤៤៩**នាក់) អនីតិជន **៣.១៧៥**នាក់ (ស្រី**១.១៤៨**នាក់)។
    - ដាច់ការទាក់ទងចំនួន **៦៧២**នាក់ (ស្រី**២៩៦**នាក់) អនីតិជន **១០៥**នាក់(ស្រី**២៩**)។
- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់មកវិញដោយខ្លួនឯងពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន **១២៤.១៤៦**នាក់ (ស្រី**៥៨.៥៤៤**នាក់) អនីតិជន **៤៦២**នាក់ (ស្រី **១៧៣**នាក់)។
- **កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ** បានធ្វើការទប់ស្កាត់ពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកទៅប្រទេសថៃដោយខុសច្បាប់ ចំនួន ០៨លើក មនុស្សចំនួន **១៣២**នាក់(ស្រី **៥១**នាក់ កុមារ **១៦**នាក់) បានធ្វើកិច្ចសន្យាអប់រំ ណែនាំរួចឱ្យត្រឡប់ទៅលំនៅដ្ឋានវិញ។

**២.៣. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តក្រចេះ សៀមរាប ស្វាយរៀង និងខេត្តកែប បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញារកម្ម ដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា បានចំនួន **៣៤**គោលដៅ មនុស្សចំនួន **៣៣៧**នាក់(ស្រី**២៤៧**នាក់)។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តក្រចេះ បាត់ដំបង ព្រះវិហារ និងខេត្តតាកែវ បានល្បាតឃ្លាំមើលគោលដៅសង្ស័យប្រព្រឹត្តបទល្មើស ចំនួន **២៥**លើក។ 

**២.៤. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

▪ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ( **ក្រុមការងារអនុវត្តច្បាប់**) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យសុំចុះបញ្ជីការរៀបអាពាហ៍ពិពាហ៍ បានចំនួន **១៤១**នាក់(ស្រី**១៤**នាក់) មាន **១៣**សញ្ជាតិ ហើយបានវាយតំលៃបញ្ជូនឱ្យក្រុមការងារប្រកចេញចូលតែមួយបានចំនួន **១១៩**នាក់(ស្រី**១៨**នាក់)។ បានប្រមូលព័ត៌មានពីសុខទុក្ខនារីខ្មែរ ដែលរៀបការទៅរស់នៅប្រទេសកូរ៉េខាងត្បូងតាមរយៈទូរស័ព្ទ ចំនួន **០២**នាក់(ស្រី) មានសេចក្តីសុខធម្មតា។

**៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

- **ខេត្តព្រះសីហនុ៖**
  - ផ្នែកការពារសុវត្ថិភាពកុមារ អង្គការម្លប់តាប៉ាង បានដាក់បណ្តាញម៉ូតូឌុបនិងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្តាញតាមសហគមន៍ ផ្នែកភ្នាក់ងារទេសចរណ៍ សរុបចំនួន **១.១៣៣**នាក់។
  - ក្រុមលេខាធិការដ្ឋាន ដែលសម្របសម្រួលដោយមន្ទីរកិច្ចការនារី សហការជាមួយក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្រុង/ស្រុក បានចុះផ្សព្វផ្សាយស្តីពី សុវត្ថិភាពកុមារនៅលើប្រព័ន្ធអនឡាញ ក្រោមប្រធានបទ "ស្វែងយល់ពីការប្រើប្រាស់អ៊ិនធើណែតរបស់កុមារកម្ពុជា" ក្នុងគោលបំណងទប់ស្កាត់ការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ តាមប្រព័ន្ធអនឡាញ ចំនួន**០២**លើក មានអ្នកចូលរួមសរុប **១០៦**នាក់ ស្រី**៧៩**នាក់។
- **ខេត្តសៀមរាប៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះតាមដានត្រួតពិនិត្យ និងស្រង់ទិន្នន័យកុមារ និងគ្រួសារ នៅតាមសិប្បកម្មផលិតផ្ទះ ចំនួន ១២កន្លែង នៅក្នុងស្រុកជីក្រែង និងស្រុកក្រឡាញ់ ដែលមានកម្មករសរុប ៣៧៨នាក់ ស្រី២០៦នាក់ ដោយរកឃើញថាពុំមានការប្រើប្រាស់កម្លាំងពលកម្មជាកុមារទេ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

**១. ការងារអនុវត្តច្បាប់**

**១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ**

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន **១៨**ករណី/**០៦**ករណី (ធៀបនឹងខែមេសា កើន**១២**ករណី ស្មើនឹង **២០០%**) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន **២០**នាក់ (ស្រី**០៣**នាក់) ជនសង្ស័យជាអនីតិជន**០៣**នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន **៥១**នាក់(ស្រី**៤៥**នាក់) មាន៖ អាយុក្រោម១៥ឆ្នាំ **១៣**នាក់ អាយុ១៥-១៧ឆ្នាំ ០៨នាក់ និងអាយុ១៨ឆ្នាំឡើង **៣០**នាក់ (ប្រគល់ឱ្យគ្រួសារ **៥១**នាក់) ក្នុងនោះចែកជា៖

❖ **ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន **០១**ករណី/**០០**ករណី ឃាត់ខ្លួនជនសង្ស័យចំនួន **០១**នាក់។ សង្គ្រោះជនរងគ្រោះ ចំនួន **០៧**នាក់(ស្រី**០១**នាក់) មាន៖ អាយុ១៨ឆ្នាំឡើង **០៧**នាក់ (ប្រគល់ឱ្យគ្រួសារ ០៧នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ (ស្រី) | ជនសង្ស័យ |
|---|---|---|---|
| -ការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០១ | ០៧ (០១) | ០១ |
| *សរុប* | ***០១ ករណី*** | ***០៧ (០១) នាក់*** | ***០១ នាក់*** |

❖ ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ១៧ករណី/០៦ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ១៩នាក់(ស្រី០៣នាក់) ជនសង្ស័យជាអនីតិជន ០៣នាក់។ សង្គ្រោះជនរងគ្រោះចំនួន ៤៤នាក់(ស្រី២២នាក់) មាន: អាយុក្រោម១៥ឆ្នាំ ១៣នាក់ អាយុ១៥-១៧ឆ្នាំ០៨នាក់ និងអាយុ១៨ឆ្នាំឡើង២៣នាក់ (ប្រគល់ឱ្យគ្រួសារ ៤៤នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ (ស្រី) | ជនសង្ស័យ |
|---|---|---|---|
| -សញ្ញារកម្ម | ០២ | ២៩ (២៩) | ០៤ |
| -រូបភាពនិងសម្ភារៈអាសអាភាស | ០១ | ០១ (០១) | ០១ |
| -រូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ | ០១ | ០១ (០១) | ០១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៩ | ០៩ (០៩) | ០៩(អនី.៣) |
| -អំពើអាសប្រាថាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៤ | ០៤ (០៤) | ០៤ |
| *សរុប* | *១៧ ករណី* | *៤៤ (៤៤) នាក់* | *១៩ នាក់ (អនី.៣)* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

**១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់**

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា ចំនួន ១.៤៤៤នាក់(ស្រី៥៤៣នាក់ កុមារា៩១នាក់ កុមារី ៧៩នាក់) ក្នុងនោះមាន៖

  - មកពីប្រទេសចិន ចំនួន៤៤នាក់ ស្ត្រី៤៣នាក់ បានសម្ភាសន៍ចំនួន ១៩នាក់(ករណីអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ/បង្ខំ ១៨នាក់ និងជួញដូរកម្លាំងពលកម្ម ០១នាក់) មិនទាន់សម្ភាសន៍ ២៥នាក់។

  - **មណ្ឌលសំចតប៉ោយប៉ែត** ពលករចំណាកស្រុកដែលបញ្ជូនត្រឡប់មកពីប្រទេសថៃ ចំនួន ១.៤០០នាក់ (បុរស៧៣០នាក់ ស្រី៥០០នាក់ កុមារា៩១នាក់ កុមារី៧៩នាក់) ក្នុងនោះបានសម្ភាសន៍កំណត់អត្តសញ្ញាណរកមុខសញ្ញាជនរងគ្រោះ០៤ ជនងាយរងគ្រោះ០៥ និងកុមារមិនមានមនុស្សអមដំណើរមកជាមួយ និងផ្តល់ការស្នាក់នៅរយៈពេលខ្លីក្នុងមណ្ឌលសំចត មុនពេលបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ និងសហគមន៍វិញបានចំនួន ១៦នាក់ ស្រី០៨នាក់។

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

  - **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន៖** បានសម្ភាសន៍ជនរងគ្រោះ ដែលបានវិលត្រឡប់មកពីប្រទេសចិន ចំនួន ២១នាក់(ស្រី) ក្នុងនោះករណីរងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ ១៩នាក់ និងស្នាក់នៅខុសច្បាប់ ០២នាក់។

  - **ខេត្តកោះកុង៖** បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរប្រទេសថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ០៥លើក មនុស្សចំនួន ១២នាក់(ស្រី០៣នាក់)។

  - **ខេត្តស្វាយរៀង៖** បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរវៀតណាមបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ០២លើក មនុស្សចំនួន ២៧នាក់(ស្រី១៨នាក់) កុមារ ១៨នាក់ (កុមារី១៣នាក់)។

១.២. ការបិទករណី

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** សហការជាមួយអង្គការក្តីសង្ឃឹម និងយុត្តិធម៌ សម្របសម្រួល បិទករណីជនរងគ្រោះដោយអំពើជួញដូរមនុស្ស (ករណីជួញដូរផ្លូវភេទ) ចំនួន ០១ករណី ជនរងគ្រោះ ០១នាក់(ស្រី) មានស្រុកកំណើតនៅភូមិដូនសុខ ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប។
- **ខេត្តបាត់ដំបង៖ អង្គការក្តីសង្ឃឹមនៃយុត្តិធម៌** បានសហការ បិទករណីកុមាររងគ្រោះដោយសារការជួញដូរ ចំនួន ០២ករណី នៅស្រុកបវេលចំនួន ០១ករណី និងក្រុងបាត់ដំបងចំនួន ០១ករណី។

**២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សទៅមណ្ឌលស្តារនីតិសម្បទា សរុបចំនួន ៤៣នាក់ ស្រី៤២នាក់(អាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ/បង្ខំ)។

**៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះ និងសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស អំពើអាជីវកម្មផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញចំនួន ១៤នាក់(ស្រី) ជាករណីអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ/បង្ខំ ១៤នាក់។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

**១. ការងារបណ្តុះបណ្តាល**

- **ខេត្តកំពង់ចាម៖** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានបើកវគ្គបណ្តុះបណ្តាលមន្ត្រី ក្រុង ស្រុក និងឃុំ សង្កាត់ ស្តីពីមុខងារពាក់ព័ន្ធនិងកិច្ចការពារកុមារ ចំនួន ១លើក នៅសាលប្រជុំស្រុកកំពង់ត្រឡាច មានអ្នកចូលរួម ២៨នាក់ ស្រី១២នាក់។
- **ខេត្តស្វាយរៀង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយក្រុមហ៊ុនចំនួន៣ បើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ច្បាប់ស្តីពីការងារ សុខភាព និងសុវត្ថិភាព ការងារ និងការជួយសង្គ្រោះបឋម ចំនួន០៣វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៤២នាក់ ស្រី ២៩នាក់។
- **ខេត្តសៀមរាប៖** ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សស្រុកពួក សហការជាមួយអង្គការកល្យាណមិត្ត បើកវគ្គបណ្តុះបណ្តាលស្តីពី ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដល់ក្រុមប្រឹក្សាឃុំ មេភូមិ ប្រជាការពារ បានចំនួន ០១លើក មានអ្នកចូលរួម ៣០នាក់ ស្រី០៣នាក់។
- **បាត់ដំបង៖**

- **លេខាធិការដ្ឋាន គ.ជ.ប.ជ** សហការជាមួយអង្គការអេ២១ និងអង្គការការីតាស់ស្វីស បើកវគ្គបណ្តុះបណ្តាលបំប៉នជំនាញអំពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងសម្ភាសបែកកោសសល្យវិច្ច័យ ដល់អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធនានា ចំនួន ០១វគ្គ មានអ្នកចូលរួម ៥៦នាក់ ស្រី ៣០នាក់។

- **អង្គការសាម៉ារីតាន់កឹស** បើកវគ្គបណ្តុះបណ្តាលអំពីចំណាកស្រុកដោយសុវត្ថិភាព និងទប់ស្កាត់ការជួញដូរមនុស្ស ដល់យុវជន នៅភូមិអូរគ្រាវជូរ ឈើទាល ពោធិ៍ជ្រៃ និងភូមិស្រឡៅជ្រុំ ឃុំសិរីមានជ័យ និងភូមិប្រឡាយប្រាក់ ឃុំអង្គរបាន និងភូមិទួលជ្រៃ ឃុំសំពៅលូន និងភូមិអូរ ឃុំសន្តិភាព ចំនួន០២វគ្គ មានអ្នកចូលរួម ៩៩នាក់ ស្រី៦១នាក់។

២. សិក្ខាសាលា

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** សហការជាមួយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) រៀបចំសិក្ខាសាលាពិគ្រោះយោបល់ដើម្បីបង្កើតជាតុចូលលើឧបសម្ព័ន្ធ នៃផែនការសកម្មភាព នៃនីតិវិធីប្រតិបត្តិបទដ្ឋាន សម្រាប់ការគ្រប់គ្រងករណីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ ដោយអំពើជួញដូរមនុស្សរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ក្រោមអធិបតីភាព ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួង។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ១. ក្នុងប្រជុំក្នុងប្រទេស

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញដឹកនាំ៖ **១.**កិច្ចប្រជុំពិភាក្សា កម្រិតបច្ចេកទេសថ្នាក់ជាតិបន្ត ដើម្បីពិនិត្យ និងសម្រេចផែនការជាតិ សម្រាប់ការអនុវត្ត GCM នៅកម្ពុជា ដោយមានកិច្ចសហប្រតិបត្តិការរវាង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយនឹងអង្គការ IOM នៅទីស្តីការក្រសួងមហាផ្ទៃ។ **២.**កិច្ចប្រជុំវិសាមញ្ញរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។ **៣.**កិច្ចប្រជុំកម្រិតបច្ចេកទេស ស្តីពីប្រព័ន្ធបញ្ជូនថ្នាក់ជាតិ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាមួយតំណាង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អង្គការ IOM អង្គការ UNDP និងអង្គការ JICA មានអ្នកចូលរួមចំនួន **២៤**នាក់ ស្រី**០៨**នាក់។ **៤.**កិច្ចប្រជុំត្រួតពិនិត្យកម្លាំងរួមវេនទី១ ស្តីពីការពង្រឹងបែបបទ និងវឌ្ឍនភាពការងារ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **៥.**កិច្ចប្រជុំស្តីពី ការរៀបចំផែនការអនុវត្តគោលនយោបាយជាតិ សុខភាពជនទេសន្តរប្រវេសន៍ ជាមួយក្រុមការងារពាក់ព័ន្ធ អង្គការ IOM នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** សហការជាមួយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) រៀបចំកិច្ចប្រជុំបច្ចេកទេសលើឧបសម្ព័ន្ធផែនការសកម្មភាព នៃនីតិវិធីប្រតិបត្តិបទដ្ឋាន សម្រាប់ការគ្រប់គ្រងករណីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ ដោយអំពើជួញដូរមនុស្សរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ។

### ២. ជំនួបពិភាក្សាការងារ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**
  - **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** បានទទួលជួបសំណេះសំណាលការងារ ជាមួយលោកស្រី Sara Lou Arriola ប្រធានអង្គការ IOM ប្រចាំអាស៊ីប៉ាស៊ីហ្វិក រួមនិងសហការី នៅវិមានសន្តិភាព។
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានទទួលជួបពិភាក្សាការងារ អំពីកិច្ចសហការជាមួយលោកស្រី Alex Mcintosh ប្រធានអនុវត្តគម្រោងនៃអង្គការ IOM និងសហការី លោកមេធាវី **សេក សារឿន** និងលោកស្រី **ហុក វិចិត្រ** អ្នកប្រឹក្សាផ្នែកច្បាប់ របស់អង្គការ IJM នៅសាលប្រជុំ គ.ជ.ប.ជ។
  - លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានទទួលជួបពិភាក្សាការងារជាមួយលោក Ky Blackman (Commander Blackman) មេបញ្ជាការកងកម្លាំងព្រំដែនអូស្ត្រាលី ជាប្រធានក្រុមប្រតិបត្តិការ ពិសេស ភ្នាក់ងារចម្រុះការពារអធិបតេយ្យភាពព្រំដែនអូស្ត្រាលី និងសន្តិសុខព្រំដែនសមុទ្រ ប្រចាំកម្ពុជា និងសហការី ដែលទើបតែងតាំងថ្មី និងលោកតំណាងអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំកម្ពុជា ស្តីពី កិច្ចសហប្រតិបត្តិការរវាងកម្ពុជា និង អូស្ត្រាលី លើកិច្ចការងារទាក់ទងនឹងអំពើជួញដូរមនុស្ស។

- **ខេត្តសៀមរាបៈ** ក្រុមការងារ គ.ខ.ប.ជ បានទទួលជួបពិភាក្សាការងារជាមួយៈ ១.អង្គការមូលនិធិអេ២១ និងអង្គការជីវិតនៅកម្ពុជា ស្តីពីការរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពអំពីច្បាប់ស្តីពី យុត្តិធម៌អនីតិជន ការកំណត់អត្តសញ្ញាណជនរងគ្រោះ កិច្ចការពារកុមារ និងការផ្តល់សេវាសមស្របដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ០១លើក ។ ២.ផ្តល់បទសម្ភាសន៍តាមប្រព័ន្ធអនឡាញជាមួយ អ្នកស្រាវជ្រាវ និងវាយតម្លៃរបស់អង្គការដែនដីមនុស្សហូឡង់ ស្តីពី ការប្រមូលទិន្នន័យដើម្បីគ្រាសម្រាប់ការអនុវត្តគម្រោងសុវត្ថិភាព និងសិទ្ធិកុមារតាមប្រព័ន្ធអនឡាញ (ស្រួល) នៅក្នុងប្រទេសកម្ពុជា ០១លើក។ ៣.បានទទួលជួបផ្តល់បទសម្ភាសន៍ជាមួយ អ្នកជំនាញការជប៉ុន (ទីប្រឹក្សាគម្រោងប្រចាំក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា) អំពីការផ្តល់សេវាជនរងគ្រោះ ដោយផ្តោតលើការកំណត់អត្តសញ្ញាណ ការការពារ និងការវាយតម្លៃអំពីតម្រូវការ និងវិសាលភាពសម្រាប់ការកែសម្រួលគោលការណ៍ណែនាំ ស្តីពីការកំណត់អត្តសញ្ញាណ និងការកសាងយន្តការបញ្ជូន បានចំនួន ០១លើក។

### គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ៤៨លើក មានអ្នកចូលរួមសរុប ៧៨៦នាក់(ស្រី ៤០៥នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១៧លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ០២លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ២៩លើក។(**ឧបសម្ព័ន្ធ១**)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់ៈ

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។

### គ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែមិថុនា ឆ្នាំ ២០២៣

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "**គ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍ ការឆ្លងដែនមិនប្រក្រតី**" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.........................ខែ..................ឆ្នាំ ថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី.........ខែ.........ឆ្នាំ២០២៣

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ ប៊ុនអេង

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"**ដើម្បីគោរពជូនជាសេចក្តីរាយការណ៍**"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

-**ដើម្បីជូនជ្រាប**-

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៤៨លើក) មនុស្សចំនួន ៧៨៦នាក់ (ស្រី ៤០៥នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញ៖<br>- បានដឹកនាំគណៈប្រតិភូ គ.ជ.ប.ជ ជួបសំណេះសំណាលជាមួយពលករខ្មែរដែលកំពុងធ្វើការនៅប្រទេសថៃ ក្នុងខេត្តនុនថៈបូរី ឈុនបូរី និងខេត្តសៈមុតប្រាកាន ដែលមានថ្នាក់ដឹកនាំស្ថាប័នជំនាញចំនួន **១៣**រូប។<br>- ចូលរួមក្នុងកិច្ចប្រជុំពិភាក្សាផ្ទៃក្នុងក្រសួងមហាផ្ទៃ ដើម្បីដោះស្រាយបញ្ហាពលករដែលកំពុងស្នាក់នៅដែលគ្មានឯកសារ និងកំពុងប្រើប្រាស់ឯកសារធ្វើការងារដែលផុតសុពលភាព នៅប្រទេសថៃ ក្រោមការដឹកនាំដោយ ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញ៖<br>- ចូលរួមកិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេសថ្នាក់ជាតិបន្ត ដើម្បីពិនិត្យ និងសម្រេចផែនការជាតិសម្រាប់ការអនុវត្ត GCM នៅកម្ពុជា ដោយមានកិច្ចសហប្រតិបត្តិការរវាង អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ និងអង្គការ IOM ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- ចូលរួមកិច្ចប្រជុំវិសាមញ្ញមួយដឹកដោយ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។<br>- ចូលរួមក្នុងកិច្ចប្រជុំពិភាក្សាផ្ទៃក្នុងក្រសួងមហាផ្ទៃដើម្បីដោះស្រាយបញ្ហាពលករ ដែលកំពុងស្នាក់នៅដែលគ្មានឯកសារ និងកំពុងប្រើប្រាស់ឯកសារធ្វើការងារដែលផុតសុពលភាព នៅប្រទេសថៃ ក្រោមការដឹកនាំដោយ ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- ចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេស ស្តីពីប្រព័ន្ធបញ្ជូនថ្នាក់ជាតិ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាមួយតំណាង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អង្គការ IOM អង្គការ UNDP និងអង្គការ JICA មានអ្នកចូលរួមចំនួន **២៤**នាក់ ស្រី០៨នាក់។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ០៩ច្បាប់ លិខិតចូល ១៣ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ២៣ច្បាប់ លិខិតចូល ០៧ច្បាប់។<br>- ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន ៧៦ច្បាប់។<br>- អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន ៣៨សកម្មភាព។<br>- អាប់ឡូតឯកសារចូលបណ្ណាល័យវីគីបានចំនួន ១៥ច្បាប់។ |

- **ក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់**
  - បានសហការជាមួយ និយ័តករទូរគមនាគមន៍កម្ពុជា (TRC) ជម្រុញក្រុមហ៊ុនទូរស័ព្ទធ្វើការផ្សព្វផ្សាយ សារអប់រំដល់ប្រជាពលរដ្ឋ តាមរយៈទូរស័ព្ទចល័ត ដើម្បីអបអរទិវាកុមារអន្តរជាតិ ១មិថុនា ឆ្នាំ២០២៣ ដែលមានខ្លឹមសារថា "រាល់ទម្រង់រំលោភបំពាន និងការជួញដូរកុមារជាបទល្មើសឧក្រិដ្ឋ"។
- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**
  - **ឯកឧត្តម អគ្គលេខាធិការរង** និងលោកអនុប្រធានក្រុមបានចូលរួម៖ ១.កិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីរៀបចំសូចនាករផែនការសកម្មភាពឆ្នាំ២០២៣-២០២៥ របស់ថ្នាក់ជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ ដែលរៀបចំដោយអង្គការ IOM UN migration ក្រោមអធិបតីភាព ឯកឧត្តម **ម៉ៅ តាន់អ៊ាន** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល មានអ្នកចូលរួមចំនួន **២៦**នាក់ ស្រី**០៦**នាក់ នៅសណ្ឋាគារសាន់វ៉េភ្នំពេញ។ ២.សិក្ខាសាលាពិគ្រោះយោបល់ ស្តីពី នីតិវិធីប្រតិបត្តិបទដ្ឋានសម្រាប់ការគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ និងអង្គការ NGOs ពាក់ព័ន្ធ ក្រោមអធិបតីភាពឯកឧត្តម **ញ៉ឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួង ស.អ.យ មានអ្នកចូលរួម **៣៧**នាក់ ស្រី**១០**នាក់ នៅសណ្ឋាគារ SunMoon។ ៣.សិក្ខាសាលាផ្សព្វផ្សាយ និងបញ្ចប់គម្រោង(បង្កើតកន្លែងធ្វើការប្រកបដោយសុវត្ថិភាព និងមានការគោរពក្នុងឧស្សាហ៍កម្មកាត់ដេរ) មានសិក្ខាកាមចូលរួម **៥៦**នាក់ នៅ HOTEL HIWARY ។
  - លោកប្រធានក្រុម អមដំណើរ **លោកជំទាវ អគ្គលេខាធិការ** ចូលរួមពិនិត្យសេចក្តីព្រាងច្បាប់ស្តីពី កិច្ចការពារកុមារ ក្រោមអធិបតីភាពលោកជំទាវ **ខៀវ បូរី** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារភ្នំពេញ មានអ្នកចូលរួម **១៧**នាក់ ស្រី០៤នាក់។
- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**
  - **លោកជំទាវ អគ្គលេខាធិការរង** បានអញ្ជើញចូលរួម៖ ១.កិច្ចប្រជុំពិភាក្សាផ្ទៃក្នុងក្រសួងមហាផ្ទៃ ដើម្បីដោះស្រាយបញ្ហាពលករដែលកំពុងស្នាក់នៅ ដែលគ្មានឯកសារ និងកំពុងប្រើប្រាស់ឯកសារធ្វើការងារដែលផុតសុពលភាពនៅប្រទេសថៃ ក្រោមការដឹកនាំដោយ ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ។ ២.ជួបពិភាក្សាការងារអំពីកិច្ចសហការជាមួយអង្គការ IJM និងIOM លើកម្មវិធីបណ្តុះបណ្តាលការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប ផ្អែកលើគោលការណ៍ណែនាំដែលបានកែសម្រួលថ្មី នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ៣.ដឹកនាំកិច្ចប្រជុំផ្ទៃក្នុងស្តីពី ការរៀបចំទម្រង់របាយការណ៍ប្រចាំសប្តាហ៍ និងរៀបចំបែងចែកតួនាទីមន្ត្រី តាមអនុសាសន៍ណែនាំរបស់ **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**។ ៤.កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានលើកទី១៩ ស្តីពីក្រុមការងារឧក្រិដ្ឋកម្មឆ្លងដែន ស្តីពីការជួញដូរមនុស្ស (TIP) តាមប្រព័ន្ធអនឡាញ ដែលបានរៀបចំនៅទីស្តីការក្រសួងមហាផ្ទៃ។
- **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**
  - **ឯកឧត្តម ឧត្តមសេនីយ៍ឯក អគ្គលេខាធិការរង** បាន៖ ១.អមដំណើរលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ទៅប្រមូលទិន្នន័យបឋមស្តីពីស្ថានភាពពលករ ដែលបាននិងកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ។ ២.ចូលរួមជួបពិភាក្សាការងារជាមួយមេបញ្ជាការគណៈប្រតិបត្តិការ នៃកិច្ចការព្រំដែនអូស្ត្រាលីដែលទើបតែងតាំងថ្មី និងលោកតំណាងអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំកម្ពុជា ស្តីពី កិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងអូស្ត្រាលីលើកិច្ចការងារទាក់ទងនឹងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព **លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ**។ ៣.ចូលរួមក្នុងកិច្ចប្រជុំពិភាក្សាផ្ទៃក្នុងក្រសួងមហាផ្ទៃ ដើម្បីដោះស្រាយបញ្ហាពលករដែលកំពុងស្នាក់នៅដែលគ្មានឯកសារ និងកំពុងប្រើប្រាស់ឯកសារធ្វើការងារដែលផុតសុពលភាព នៅប្រទេសថៃ ក្រោមការដឹកនាំដោយឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ។

| | |
|---|---|
| | - លោកប្រធាន និងលោកអនុប្រធានក្រុម បានចូលរួមសិក្ខាសាលាស្តីពី ការពិនិត្យលទ្ធភាពនៃការសិក្សាលើកពង្រឹងការណែនាំតម្រង់ទិសពលករមុនចេញដំណើរទៅធ្វើការនៅប្រទេសថៃ ក្រោមអធិបតីភាពឯកឧត្តម **ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសណ្ឋាគារភ្នំពេញ។<br>- បានចូលរួមស្តីពីការបង្ហាញកំណត់ពន្យល់សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារដល់ក្រុមការងារបច្ចេកទេស នៃក្រសួង ស្ថាប័ន ពាក់ព័ន្ធ ក្រោមអធិបតីភាពឯកឧត្តម **ថេង ធវិទ្ធិ** អនុប្រធានអចិន្ត្រៃយ៍ នៃលេខាធិការដ្ឋាន និងលោកជំទាវ **ខៀវ បូរី** រដ្ឋលេខាធិការក្រសួង ស.អ.យ និងជាប្រធានក្រុមការងារបច្ចេកទេស នៅសណ្ឋាគារសាន់វ៉េ។<br>- បានចូលរួមសិក្ខាសាលាអន្តរក្រសួង ស្តីពីការអភិវឌ្ឍផែនការសកម្មភាពដើម្បីដោះស្រាយភាពខ្វះចន្លោះក្នុងការផ្តល់សេវាសមាហរណកម្មដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពឯកឧត្តម **តូច ចាន់នី** អគ្គនាយក នៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច នៅសណ្ឋាគារសោម៉ាទេវី ខេត្តសៀមរាប ។ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | - បានសម្របសម្រួលឱ្យទីប្រឹក្សាគម្រោងរបស់ JICA បានជួបសម្ភាសន៍ជាមួយ ស្នងការរងខេត្តបន្ទាយមានជ័យ មន្ត្រីមកពីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរអប់រំ យុវជន និងកីឡា មន្ទីរសុខាភិបាល និងមន្ទីរកិច្ចការនារី នៅខេត្តបន្ទាយមានជ័យ ០២លើក។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ២៩លើក អ្នកចូលរួមសរុបចំនួន ៦១៣នាក់(ស្រី ៣៧៧នាក់)** | |
| **ខេត្តកណ្តាល** | - លេខាធិការដ្ឋាន គ.ខ.ប.ជ រៀបចំកិច្ចប្រជុំបូកសរុបរបាយការណ៍ប្រចាំខែ ០១លើក មានអ្នកចូលរួម ២៨នាក់ ស្រី២១នាក់។<br>- ក្រុមការងារក្រុង-ស្រុក ប្រជុំប្រចាំខែ ចំនួន ០៦លើក អ្នកចូលរួម ១៣៧នាក់ ស្រី៨០នាក់។ |
| **ខេត្តកំពង់ចាម** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យលទ្ធផលការងារប្រចាំខែឧសភា ០១លើក។ |
| **ខេត្តកំពង់ធំ** | - តំណាងលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការអនុវត្តនីតិវិធីប្រតិបត្តិការស្តង់ដារសម្រាប់ប្រព័ន្ធទូរស័ព្ទជំនួយប្រកបដោយគុណភាពក្នុងការឆ្លើយតបចំពោះករណីអំពើហិង្សាលើស្ត្រី រួមទាំងពលករទេសន្តរប្រវេសន៍ជាស្ត្រី នៅសណ្ឋាគារកំពង់ធំរ៉ូយ៉ាល់ ០១លើក។ |
| **ខេត្តកំពត** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំការងារពាក់ព័ន្ធ ០១លើក មានអ្នកចូលរួម ២៩នាក់ ស្រី ១៥នាក់។ |
| **ខេត្តកំពង់ឆ្នាំង** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែ ០១លើក។ |
| **ខេត្តព្រះវិហារ** | - មន្ទីរកិច្ចការនារី បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ ស្តីពី ការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចនានា និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ០១លើក។ |
| **ខេត្តបន្ទាយមានជ័យ** | - **ក្រុមការងារ គ ជ.ប.ខ.**បាន៖ ១.នាំយកសម្ភារៈជូនប្រជាពលរដ្ឋដែលធ្លាប់ជាអតីតពលករ ក្រុងសិរីសោភ័ណ ចំនួន៥គ្រួសារ និងបានបញ្ជ្រាបអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ជាជាងការធ្វើចំណាកស្រុកទាំងប្រថុយប្រថាន។ ២.ឯកឧត្តម **អ៊ុំ រាត្រី** ប្រធានគ ជ.ប.ខ.បានចុះជួសជុលផ្ទះប្រជាពលរដ្ឋរងគ្រោះដោយខ្យល់កន្ត្រាក់ចំនួន ២៣០ខ្នង និងបញ្ជ្រាបអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ជាជាងការធ្វើចំណាកស្រុកទាំងប្រថុយប្រថាន។ |

| | |
|---|---|
| **ខេត្តកំពង់ស្ពឺ** | - **តំណាងមន្ទីរកិច្ចការនារី បាន៖**<br>○ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ស្តីពីអំពើជួញដូរមនុស្ស ការប្រវ័ញ្ចនានា និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន នៅខេត្តមណ្ឌលគីរី មានអ្នកចូលរួម ៤២នាក់ ស្រី ៣៤នាក់។<br>○ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់ផ្តល់ការឆ្លើយតបប្រកបដោយគុណភាពចំពោះករណីអំពើហិង្សាលើស្ត្រី រួមទាំងអំពើហិង្សាលើពលករទេសន្តរប្រវេសន៍ស្ត្រី តាមរយៈបណ្តាញទូរស័ព្ទផ្តល់ជំនួយ នៅសណ្ឋាគារកំពង់ធំរ៉ូយ៉ាល់ មានអ្នកចូលរួម ៥៥នាក់ ស្រី៣៩នាក់។<br>○ចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីពីការជួញដូរមនុស្ស និងចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅស្រុកឱរ៉ាល អ្នកចូលរួម ១៨នាក់ ស្រី០៦នាក់។ |
| **ខេត្តសៀមរាប** | - បានចូលរួមសិក្ខាសាលាស្តីពី ការទប់ស្កាត់អំពើជួញដូរមនុស្ស នៅតាមសាលារៀនក្នុងស្រុកពួក និងស្រុកក្រឡាញ់ ដែលរៀបចំដោយមន្ទីរអប់រំយុវជន និងកីឡា សហការជាមួយអង្គការហាការ មានអ្នកចូលរួម ៤០នាក់ ស្រី២២នាក់។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែ ០១លើក មានអ្នកចូលរួម ៦០នាក់ ស្រី៣៦នាក់។<br>- ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក បានរៀបចំកិច្ចប្រជុំ ០៨ លើក/ ៨ស្រុក មានអ្នកចូលរួម ១៩៩នាក់ ស្រី៨៨នាក់។ |
| **ខេត្តព្រៃវែង** | - តំណាងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចូលរួមសិក្ខាសាលាអន្តរក្រសួង ស្តីពីការអភិវឌ្ឍន៍ផែនការសកម្មភាពដើម្បីដោះស្រាយភាពខ្វះចន្លោះក្នុងការផ្តល់សេវាសមាហរណកម្មដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ០១លើក មានអ្នកចូលរួម ៦៣នាក់។<br>- តំណាងមន្ទីរកិច្ចការនារី បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចនានា និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ០១លើក នៅខេត្តរតនគិរី មានអ្នកចូលរួម ៤២នាក់ ស្រី៣៦នាក់។ |